ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ២០៣ ប្រក កសក

# ប្រកាស

# ស្តីពី

# បែបបទ និង នីតិវិធីសម្រាប់ការស្នើសុំ និង ការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ. បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧ ស្តីអំពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ. បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ
- បានឃើញប្រកាសលេខ ០៨៦ប្រក.កសក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៤ ស្តីពីការដាក់ឱ្យប្រើបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា
- តាមសំណើរបស់នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ⁄

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd. Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

# សម្រេច

**ប្រការ ១ :** ប្រកាសនេះកំណត់នូវបែបបទ និង នីតិវិធីសម្រាប់ការស្នើសុំ និង ការផ្ដល់វិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា ក្នុងគោលបំណងធានាបាននូវលក្ខខណ្ឌសមស្របក្នុងការស្នើសុំសម្រាប់អ្នកកែច្នៃកៅស៊ូ ឬ អ្នកនាំចេញកៅស៊ូ សំដៅផ្ដល់នូវជំនឿទុកចិត្តដល់ទីផ្សារជាតិ និង អន្តរជាតិ ក្នុងការធ្វើពាណិជ្ជកម្មកៅស៊ូដែលមានប្រភពដើមផលិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២ :** អ្នកកែច្នៃកៅស៊ូ ឬ អ្នកនាំចេញកៅស៊ូ ដែលស្នើសុំវិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា ត្រូវធ្វើលិខិតស្នើសុំធ្វើតេស្តមកមន្ទីរពិសោធន៍វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬ មន្ទីរពិសោធន៍មូលដ្ឋាន ដោយភ្ជាប់ជាមួយភាគសំណាកដែលមានស្លាកសម្គាល់ច្បាស់លាស់។ វិធីសាស្ត្រនៃការយកសំណាកកៅស៊ូ ដើម្បីធ្វើតេស្តគុណភាព ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១ ភ្ជាប់ប្រកាសនេះ ។

ភាគសំណាកដែលបានទទួលនៅមន្ទីរពិសោធន៍ត្រូវបានត្រួតពិនិត្យត្រឹមត្រូវ និង ត្រូវចុះក្នុងបញ្ជីទទួលភាគសំណាក រួចបិទស្លាកមន្ទីរពិសោធន៍។ អ្នកទទួលត្រូវបំពេញប័ណ្ណទទួលសំណាកចំនួន ០២ (ពីរ) ច្បាប់ និង ចុះហត្ថលេខាដោយភាគីទាំងពីរ។ ប័ណ្ណ ០១ (មួយ) ច្បាប់ផ្ដល់ឱ្យអ្នកបញ្ជូនភាគសំណាក និង ០១ (មួយ) ច្បាប់ទៀតរក្សាទុកក្នុងមន្ទីរពិសោធន៍ ។

ការធ្វើតេស្តភាគសំណាកត្រូវធ្វើឡើងស្របតាមវិធីសាស្ត្រវិភាគដែលចេញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាតាមបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា ។

**ប្រការ ៣ :** រាល់របាយការណ៍តេស្តដែលចេញឱ្យអ្នកកែច្នៃកៅស៊ូ ឬ អ្នកនាំចេញកៅស៊ូត្រូវចុះក្នុងបញ្ជីរបាយការណ៍តេស្ត ។ ក្រោយពីទទួលរបាយការណ៍តេស្ត វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬ មន្ទីរពិសោធន៍មូលដ្ឋាន ត្រូវចេញវិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជាដែលបានធ្វើតេស្តនោះជូនអ្នកស្នើសុំ។ គំរូរបាយការណ៍តេស្តចេញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និង របាយការណ៍តេស្តចេញដោយមន្ទីរពិសោធន៍មូលដ្ឋាន ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២ និងទី៣ ភ្ជាប់ប្រកាសនេះ។

អ្នកស្នើសុំមានកាតព្វកិច្ចបង់កម្រៃសេវាកម្មជូនវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬ មន្ទីរពិសោធន៍មូលដ្ឋានសម្រាប់ការធ្វើតេស្ត និង ការចេញវិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា។

**ប្រការ ៤ :** វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬ មន្ទីរពិសោធន៍មូលដ្ឋាន ត្រូវចេញវិញ្ញាបនបត្រចំនួន ០៥ (ប្រាំ) ច្បាប់ដើម ដោយត្រូវ :

-ប្រគល់ឱ្យអ្នកស្នើសុំចំនួន ០២ (ពីរ) ច្បាប់

-រក្សាទុកនៅមន្ទីរពិសោធន៍ចំនួន ០១ (មួយ) ច្បាប់

-រក្សាទុកនៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាចំនួន ០១ ( មួយ) ច្បាប់

-ប្រគល់ឱ្យភ្នាក់ងារមានសមត្ថកិច្ច ០១ ( មួយ) ច្បាប់ ជាឯកសារភ្ជាប់សម្រាប់នាំចេញ។

វិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា អាចផ្តល់ឱ្យតែរោងចក្រកែច្នៃកៅស៊ូណា ដែលបានចុះបញ្ជិកា នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាប៉ុណ្ណោះ ។

**ប្រការ ៥ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៦ :** អគ្គនាយកនៃក្រសួង អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានចំការកៅស៊ូ នាយកខុទ្ទកាល័យ នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និង ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៨

**រដ្ឋមន្ត្រី**

ចាន់ សារុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី ១ ភ្ជាប់ប្រកាសលេខ...៤០៧ ប្រក.កសក...ចុះថ្ងៃទី ...០១......ខែ...កក្កដា....ឆ្នាំ ២០០៥

# វិធីសាស្ត្រនៃការយកសំណាកកៅស៊ូដើម្បីធ្វើតេស្តគុណភាព

## ១. គោលបំណង

វិធីសាស្ត្រនេះរៀបរាប់អំពីវិធីយកសំណាកដែលតំណាងឱ្យឡូត៍ផលិតកម្ម និងការរៀបចំបញ្ជូនសំណាកទៅមន្ទីរពិសោធន៍ ។

## ២. និយមន័យ

*ឡូត៍* - សំណុំនៃដុំកៅស៊ូដែលមានប្រភេទ និងថ្នាក់ដូចគ្នា បានកែច្នៃពីវត្ថុធាតុដើម និងរក្សាទុកក្នុងលក្ខខណ្ឌដូចគ្នា ។ ទំហំឡូត៍មិនត្រូវឱ្យលើសពី ៦០០ ដុំកៅស៊ូ ។

*សំណាក* - ក្រុមដុំកៅស៊ូដែលត្រូវបានជ្រើសរើសជាតំណាងឱ្យឡូត៍ ។

*ភាគសំណាក* - កៅស៊ូដែលយកចេញពីដុំនៃសំណាក ។

*គំរូវិភាគ* - កៅស៊ូកាត់ចេញពីសំណាកបន្ទាប់ពីបានកិនឱ្យស្មើសាច់សម្រាប់ការធ្វើតេស្ត ។

## ៣. ការយកសំណាក

### *៣.១ វិធីយកសំណាក*

តាមបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា រាល់ឡូត៍ទាំងអស់ត្រូវធ្វើតេស្តយថាប្រភេទកម្ម ។ ដុំកៅស៊ូសង្កត់រូច ចំនួន ១០% ក្នុងកែសប៉ាឡែតនីមួយៗ ត្រូវបានជ្រើសរើសចេញពីឡូត៍ធ្វើជាសំណាក ។

### *៣.២ វិធីយកភាគសំណាក*

យកដុំកៅស៊ូដែលបានជ្រើសរើសជាសំណាកមកដាក់ផ្ដេកនៅលើតុស្អាត ។ កាត់យកអនុភាគសំណាកចំនួន ២ ដែលមានមុខកាត់រាងត្រីកោណនៅជ្រុងឈមពីរ ( ប្រហែល ៥ × ៥ × ៧ សម) ដោយកាំបិតស្ងួតស្អាត ។ អនុភាគសំណាកនីមួយៗមានទម្ងន់យ៉ាងតិច ១៨០ ទៅ ២០០ ក្រាម ។ ទីតាំង និងទំហំនៃអនុភាគសំណាកត្រូវបានបង្ហាញក្នុងរូបទី ១ ។ អនុភាគសំណាកទាំង ២ផ្គុំចូលគ្នាបង្កើតបានជាភាគសំណាកត្រូវបានច្រកក្នុងថង់ប៉ូលីអេទីឡែនជាមួយនឹងស្លាកដែលបំពេញនូវព័ត៌មានលំអិតចាំបាច់ ។




រូបទី ១ : ទីតាំង និងទំហំភាគសំណាក

ភាគសំណាកត្រូវបញ្ជូនទៅធ្វើតេស្ត ក្នុងរយៈពេលយ៉ាងយូរមួយសប្តាហ៍បន្ទាប់ពីការយកសំណាក ។ ស្លាកនៃភាគសំណាកមានព័ត៌មានចាំបាច់ដូចតទៅ :

- ឈ្មោះរោងចក្រ
- កាលបរិច្ឆេទនៃការកែច្នៃ
- វត្ថុធាតុដើម (ទឹកជ័រ ឬជ័រកក)
- ចំណាត់ថ្នាក់ប៉ាន់ស្មាន
- លេខឡូត៍ និងលេខកែសប៉ាឡែត
- លេខភាគសំណាក (លេខដុំកៅស៊ូ)
- វិធីកិនឱ្យស្មើសាច់

*៣.៣ ការបញ្ជូនភាគសំណាកទៅមន្ទីរពិសោធន៍សម្រាប់ធ្វើតេស្ត*

គ្រប់ភាគសំណាកទាំងអស់ត្រូវរៀបចំដាក់ក្នុងថង់ប៉ូលីអេទីឡែនធំមួយដោយមានស្លាកដូចតទៅ :

- ឈ្មោះរោងចក្រ
- ចំនួនឡូត៍ និងកែសប៉ាឡែត
- ចំនួនភាគសំណាក
- កាលបរិច្ឆេទបញ្ជូនសំណាក
- វិធីកិនឱ្យស្មើសាច់

ឧបសម្ព័ន្ធទី ២ ភ្ជាប់ប្រកាសលេខ...៤០៧ ប្រក.កសក....ចុះថ្ងៃទី ...០១.....ខែ...កក្កដា.....ឆ្នាំ ២០០៤

គំរូរបាយការណ៍តេស្តចេញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា


**Cambodian Rubber Research Institute**
**National Specifications Laboratory**


ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

# របាយការណ៍តេស្ត TEST REPORT No.________

ផ្ញើជូន ATTENTION: ____________________

ថ្ងៃខែឆ្នាំទទួលសំណាក DATE RECEIVED SAMPLES: ____________________

ថ្ងៃខែឆ្នាំផ្ញើ DATE OF LETTER: ____________________

ប្រភេទកៅស៊ូ TYPE OF RUBBER: ____________________

ចំនួនសំណាក SAMPLE SIZE: ____________________

ទម្ងន់កៅស៊ូ TONNAGE: ____________________

| លេខយោង REF. No. | លេខឡូត៍ Lot No. | លេខកែស PALLET No. | ថ្ងៃខែឆ្នាំផលិត DATE PRODUCED | ថ្ងៃខែឆ្នាំធ្វើតេស្ត DATE TESTED | អសុទ្ធភាព DIRT (%wt) | ផេះ ASH (%wt) | សារធាតុហើរ VM (%wt) | អាសូត N (%wt) | $P_0$ | PRI (%) | ពណ៌ COLOUR | វិស្កូស៊ីធីម្ពី VR | ΔP | ចំណាត់ថ្នាក់ GRADE |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| មធ្យមភាគ | | | MEAN | | | | | | | | (MAX.) | | | |
| គំលាតគំរូ | | | SD | | | | | | | | | | | |
| មធ្យមភាគបូកបីគំលាតគំរូ | | | MEAN + 3SD | | | | | | | | | | | |
| អតិបរមា | | | MAX. | | | | | | | | | | | |
| អប្បបរមា | | | MIN. | | | | | | | | | | | |

ផ្ទៀងផ្ទាត់ដោយមន្ត្រីមើលការខុសត្រូវ CHECKED BY SUPERVISORY OFFICER
..........................................................................

យល់ព្រមដោយប្រធានមន្ទីរពិសោធន៍ ,កាលបរិច្ឆេទ
APPROVED BY CHIEF OF LABORATORY ........................................ DATE

*ការធ្វើតេស្តនេះត្រូវបានអនុវត្តចំពោះសំណាកដែលទទួលដោយមន្ទីរពិសោធន៍ជាតិយថាប្រភេទស្របតាមវិធីវិភាគនៃ ISO/SMR Bulletin No. 7 ។*

*របាយការណ៍ពិសោធន៍នេះមិនអាចថតចម្លងជាថ្មីបានឡើយលើកលែងតែមានការអនុញ្ញាតជាលាយល័ក្ខអក្សរពីមន្ទីរពិសោធន៍ជាតិយថាប្រភេទនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ។*

*These tests have been carried out on the samples received by the National Specifications Laboratory (NSL) in accordance with test methods described in ISO test methods/SMR bulletinNo.7. This report shall not be reproduced except in full without the written approval of the NSL of the Cambodian Rubber Research Institute.*


*Address: 9, Penn Nouth Blvd, Boeung Kak I, Toul Kork, Phnom Penh, P.O. Box: 1337, Phnom Penh, Tel: (855) 23 882 830, Fax: (855) 23 882 831, Email: crri@camnet.com.kh*

ឧបសម្ព័ន្ធទី ៣ ភ្ជាប់ប្រកាសលេខ...៤០៧ ប្រក.កសក...ចុះថ្ងៃទី ...០១.....ខែ...[illegible]....ឆ្នាំ ២០០៥

គំរូរបាយការណ៍តេស្តចេញដោយមន្ទីរពិសោធន៍មូលដ្ឋាន

Logo of Laboratory or Plantation

**Chup Rubber Plantation**
**Specifications Laboratory**

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

## របាយការណ៍តេស្ត TEST REPORT No.________

ផ្ញើជូន ATTENTION: ____________________
ថ្ងៃខែឆ្នាំទទួលសំណាក DATE RECEIVED SAMPLES: ____________________
ថ្ងៃខែឆ្នាំផ្ញើ DATE OF LETTER: ____________________

ប្រភេទកៅស៊ូ TYPE OF RUBBER: ____________________
ចំនួនសំណាក SAMPLE SIZE: ____________________
ទម្ងន់កៅស៊ូ TONNAGE: ____________________

| លេខយោង REF. No. | លេខឡូត៍ Lot No. | លេខកែស PALLET No. | ថ្ងៃខែឆ្នាំផលិត DATE PRODUCED | ថ្ងៃខែឆ្នាំធ្វើតេស្ត DATE TESTED | អសុទ្ធភាព DIRT (% wt) | ផេះ ASH (%wt) | សារធាតុហើរ VM (% wt) | អាសូត N (% wt) | $P_0$ | PRI (%) | ពណ៌ COLOUR | វិស្កូស៊ីធីម្ញូនី VR | ΔP | ចំណាត់ថ្នាក់ GRADE |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| មធ្យមភាគ MEAN | | | | | | | | | | | (MAX.) | | | |
| គំលាតគំរូ SD | | | | | | ផ្ទៀងផ្ទាត់ដោយមន្ត្រីមើលការខុសត្រូវ CHECKED BY SUPERVISORY OFFICER ........................ | | | | | | | | |
| មធ្យមភាគបូកបីគំលាតគំរូ MEAN + 3SD | | | | | | | | | | | | | | |
| អតិបរមា MAX. | | | | | | យល់ព្រមដោយប្រធានមន្ទីរពិសោធន៍ APPROVED BY CHIEF OF LABORATORY ........................ | | | | | កាលបរិច្ឆេទ DATE | | | |
| អប្បបរមា MIN. | | | | | | | | | | | | | | |

*ការធ្វើតេស្តនេះត្រូវបានអនុវត្តចំពោះសំណាកដែលទទួលដោយមន្ទីរពិសោធន៍ជាតិយថាប្រភេទស្របតាមវិធីវិភាគនៃISO/SMR Bulletin No. 7 ។*

*របាយការណ៍ពិសោធន៍នេះមិនអាចផ្តល់ជូនជាថ្មីបានឡើយលើកលែងតែមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីមន្ទីរពិសោធន៍ជាតិយថាប្រភេទនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ។*

*These tests have been carried out on the samples received by the National Specifications Laboratory (NSL) in accordance with test methods described in ISO test methods/SMR bulletinNo.7.*
*This report shall not be reproduced except in full without the written approval of the NSL of the Cambodian Rubber Research Institute.*

៧